## កម្ពុជា៖ អ្នកប្រកបមុខរបររកស៊ីផ្លូវភេទ ប្រឈមនឹង ការចាប់ខ្លួន និងឃុំខ្លួនខុសច្បាប់
## មន្ត្រីមានសមត្ថកិច្ចត្រូវតែស៊ើបអង្កេត និងបិទមជ្ឈមណ្ឌលរដ្ឋាភិបាលដែលមានការរំលោភ

(រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១០) — អង្គការឃ្លាំមើលសិទ្ធិមនុស្សបាននិយាយនៅក្នុងរបាយការណ៍ដែលចេញផ្សាយថ្ងៃនេះថា រដ្ឋាភិបាលកម្ពុជាគួរតែធ្វើសកម្មភាព បញ្ឈប់ជាបន្ទាន់នូវរាល់អំពើហិង្សាប្រឆាំងនឹងអ្នកប្រកបមុខរបររកស៊ីផ្លូវភេទ និងគួរបិទជាស្ថាពរ នូវមជ្ឈមណ្ឌល ដែលស្ត្រីប្រកបរបររកស៊ីផ្លូវភេទទាំងឡាយត្រូវបានគេឃុំឃាំងខ្លួនដោយខុសច្បាប់ និងដោយរំលោភនៅទីនោះ។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានជំរុញផងដែរឲ្យរដ្ឋាភិបាល កម្ពុជា ព្យួរបទបញ្ញត្តិមួយចំនួននៅក្នុងច្បាប់ឆ្នាំ២០០៨ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលបញ្ញត្តិទាំងនោះសម្របសម្រួលឲ្យប៉ូលីសប្រព្រឹត្ត អំពើ យារយី និងអំពើរំលោភបំពាន។

របាយការណ៍ចំនួន៧៦ទំព័រ របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស ដែលមានចំណងជើងថា “បង្ក្រាបអ្នកប្រកបមុខរបររកស៊ីផ្លូវភេទ៖ ការឃុំខ្លួនតាមអំពើចិត្តនិងអំពើរំលោភផ្សេងទៀត ប្រឆាំងនឹងអ្នកប្រកបរបររកស៊ីផ្លូវភេទនៅក្នុងប្រទេសកម្ពុជា” ត្រូវបានធ្វើឡើងដោយផ្អែកលើ ការសម្ភាសន៍ និងការពិភាក្សាជាក្រុមជាមួយអ្នកប្រកបរបររកស៊ីផ្លូវភេទជាស្ត្រី និង ស្រីស្រស់ (Transgender) ច្រើនជាង៩០នាក់ ក្នុងរាជធានីភ្នំពេញ ខែត្របាត់ដំបង បន្ទាយមានជ័យ និងខែត្រសៀមរាប។ របាយការណ៍នេះបានពិពណ៌នានូវរបៀបដែលអ្នកប្រកបរបររកស៊ីផ្លូវភេទ ប្រឈមនឹងការរំលោភដ៏រីករាលដាល មានជាអាទិ៍ ការវាយដំ អំពើជំរិតយកលុយ និងអំពើរំលោភសេពសន្ថវៈនៅក្នុងដៃអាជ្ញាធរ ជាពិសេសនៅក្នុងរាជធានីភ្នំពេញ។

អេឡេន ភាសុន នាយកស្ដីទីប្រចាំអាស៊ីនៃអង្គការឃ្លាំមើលសិទ្ធិមនុស្សបានមានប្រសាសន៍ ថា “អស់ពេលជាយូរមកហើយ ប៉ូលីសនិងអាជ្ញាធរដទៃទៀត បានចាក់សោរបង្ខាំង អ្នកប្រកបរបររកស៊ីផ្លូវភេទដោយខុសច្បាប់ វាយដំ និងរំលោភលើផ្លូវភេទរបស់ពួកគេ ហើយលួចលុយនិងទ្រព្យសម្បត្តិដែលមានជាប់ខ្លួនរបស់ពួកគេ។ រដ្ឋាភិបាលកម្ពុជា ត្រូវតែ បញ្ជារឲ្យមានការស៊ើបអង្កេតជាបន្ទាន់ ដោយហ្មត់ចត់និងឯករាជ្យ ចំពោះអំពើរំលោភ ជាប្រព័ន្ធទៅលើសិទ្ធិមនុស្សរបស់អ្នកប្រកបមុខរបររកស៊ីផ្លូវភេទ និងត្រូវបិទមជ្ឈមណ្ឌល ដែលជាកន្លែងដែលអ្នកប្រកបមុខរបររកស៊ីផ្លូវភេទ ទទួលរងនូវអំពើរំលោភ។”

ប៉ូលីសចាប់ខ្លួនអ្នកប្រកបរបររកស៊ីផ្លូវភេទ ក្នុងវិធានការបោសសម្អាតជាទៀងទាត់តាម ដងផ្លូវនិងតាមសួនច្បារនៃរាជធានីភ្នំពេញ។ អំពើហិង្សាខ្លះជា អំពើឆ្លៀតឱកាស ចំណែកឯ អំពើរំលោភដទៃទៀតកើតឡើងជាទូទៅ នៅក្នុងវិធានការបង្ក្រាបនិង ចុះចាប់ប្រមូលតាម ពេលកំណត់របស់ប៉ូលីសនិងអាជ្ញាធរខ័ណ្ឌ ជាពិសេស នៅពេលសំដៅចាប់តែអ្នកប្រកបរបររកស៊ីផ្លូវភេទ និងនៅពេលផ្សេងទៀតសំដៅចាប់អ្នកប្រកបរបររកស៊ីផ្លូវភេទ ក្នុង ចំណោមក្រុមដទៃទៀតនៃប្រជាពលរដ្ឋដែលគេចាត់ទុកជាកាកសំណល់សង្គម ដែលគេ ឃើញនៅតាមដងផ្លូវ។

ប៉ូលីសរំលោភស្ត្រីប្រកបរបររកស៊ីផ្លូវភេទ ដោយគ្មានទទួលការផ្តន្ទាទោសឡើយ។ ស្ត្រី ប្រកបរបររកស៊ីផ្លូវភេទ បានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា មន្ត្រីប៉ូលីសបានវាយ ពួកគេដោយប្រើកណ្ដាប់ដៃ រំពាត់ ដំបងឈើ និងដំបងឆក់អគ្គីសនី។ ក្នុងកាលៈទេសៈខ្លះ មន្ត្រីប៉ូលីសបានរំលោភសេពសន្ថវៈលើស្ត្រីប្រកបរបររកស៊ីផ្លូវភេទ នៅអំឡុងពេលដែល ពួកគេស្ថិតក្នុងការឃុំឃាំងរបស់ប៉ូលីស។ ស្ត្រីប្រកបរបររកស៊ីផ្លូវភេទរាល់រូប ដែលអង្គការ ឃ្លាំមើលសិទ្ធិមនុស្សបានសម្ភាសន៍ បានបង់ប្រាក់សំណូក ឬត្រូវមន្ត្រីប៉ូលីសលួចលុយ របស់ពួកគេ។

ច្បាប់កម្ពុជាឆ្នាំ២០០៨ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានដាក់ជាបទព្រហ្មទណ្ឌនូវរាល់ទម្រង់ទាំងអស់នៃអំពើជួញដូរ រួមទាំងការងារដោយបង្ខំ។ អង្គការឃ្លាំមើលសិទ្ធិមនុស្សបានរកឃើញថា មន្ត្រីប៉ូលីសពេលខ្លះអាចប្រើផ្នែកទាំងឡាយ នៃច្បាប់ដែលដាក់ជាបទព្រហ្មទណ្ឌលើ “អំពើអូសទាញ” និង “អំពើសញ្ជារកម្ម” នៃការជួញដូរភេទ ដើម្បី បង្ហាញពីភាពត្រឹមត្រូវចំពោះអំពើយារយីរបស់ខ្លួនលើស្ត្រី ប្រកប របររកស៊ីផ្លូវភេទ ។ បទបញ្ញត្តិច្បាប់ទាំងឡាយ មានលក្ខណៈទូលំទូលាយគ្រប់គ្រាន់ សម្រាប់ប្រើប្រាស់ដាក់ជាបទព្រហ្មទណ្ឌលើសកម្មភាពស្វែងរកការគាំទ្រ និងសកម្មភាព អប់រំដោយផ្ទាល់ ដោយក្រុមអ្នកប្រកបរបររកស៊ីផ្លូវភេទ និងអ្នកទាំងឡាយដែលគាំទ្រ ពួកគេ។

អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានជំរុញឲ្យរដ្ឋាភិបាលកម្ពុជា ពិភាក្សាជាមួយក្រុមអ្នកប្រកប របររកស៊ីផ្លូវភេទ ទីភ្នាក់ងារសហប្រជាជាតិ និងអង្គការដែលធ្វើការលើ បញ្ហាសិទ្ធិមនុស្ស បញ្ហាជួញដូរមនុស្ស និងសុខភាព ដើម្បីពិនិត្យមើលឡើងវិញ បទបញ្ញត្តិច្បាប់ឆ្នាំ២០០៨ ស្ដីពីអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ និងដោះស្រាយផលប៉ះពាល់សិទ្ធិមនុស្សរបស់អ្នកទាំងឡាយដែលជាប់ពាក់ព័ន្ធក្នុងការងារប្រកបរបររកស៊ីផ្លូវភេទ មុនពេល អនុវត្តបទបញ្ញត្តិទាំងនោះ។

ភាសុន បានមានប្រសាសន៍ថា “ក្នុងបរិយាកាសមួយ ដែលប៉ូលីសប្រព្រឹត្តអំពើរំលោភច្បាប់ ដោយឥតទោសពៃរ៍ នោះរដ្ឋាភិបាលកម្ពុជាចាំបាច់ត្រូវតែទទួលស្គាល់ថា ការដាក់ជាបទព្រហ្មទណ្ឌលើ អំពើអូសទាញ គឺជារូបមន្តមួយសម្រាប់បន្តរំលោភសិទ្ធិមនុស្ស។ រដ្ឋាភិបាល គួរតែត្រឡប់ទៅរកដំណាក់កាលមួយ – ដោយចាប់ផ្តើមដំបូងពីការពិភាក្សាយ៉ាងទូលំទូលាយជាមួយក្រុមអ្នកប្រកបរបររកស៊ីផ្លូវភេទ និងក្រុមដទៃទៀត – មុនបន្តអនុវត្តបទបញ្ញត្តិ ទាំងឡាយដែល រំលោភដោយប៉ូលីស។”

នៅក្នុងរាជធានីភ្នំពេញ ប៉ូលីសបញ្ជូនអ្នកប្រកបរបររកស៊ីផ្លូវភេទ ទៅមន្ទីរសង្គមកិច្ចរាជធានី និងបញ្ជូន បន្តពីទីនោះទៅអង្គការមិនមែនរដ្ឋាភិបាល ឬមជ្ឈមណ្ឌលសង្គមកិច្ចរបស់ រដ្ឋាភិបាល ព្រៃស្ពឺ។ ស្ថានភាពនៅ ព្រៃស្ពឺ គឺដូចជានរក។  អ្នកប្រកបរបររកស៊ីផ្លូវភេទ អ្នកសុំទាន អ្នកប្រើប្រាស់គ្រឿងញៀន កុមាររស់តាមចិញ្ចើមថ្នល់ និងអ្នកគ្មានផ្ទះសំបែង ដែលគេរក្សាទុកនៅព្រៃស្ពឺ បានរាយការណ៍ពីរបៀបដែលសមាជិកបុគ្គលិកមណ្ឌលបាន វាយដំ រំលោភសេពសន្ថវៈ និងធ្វើបាបអ្នកជាប់ឃុំ រួមទាំងកុមារ។ បុគ្គលិកសិទ្ធិមនុស្ស  ក្នុងស្រុក ដែលដកស្រង់សំដីសាក្សីផ្ទាល់ភ្នែក ចោទប្រកាន់ថា យ៉ាងហោចណាស់ មនុស្ស បីនាក់ និងអាចច្រើនជាងនេះ ត្រូវបានឆ្មាំមណ្ឌលវាយ រហូតដល់ស្លាប់ នៅឯព្រៃស្ពឺ ចន្លោះ ឆ្នាំ២០០៦ និង២០០៨។

បន្ទាប់ពីមានសកម្មភាពស្វែងរកការគាំទ្រពីអង្គការជាតិ និងអន្តរជាតិ នៅក្នុងឆ្នាំ២០០៩ និង២០១០ មន្ទីរសង្គមកិច្ចរាជធានីបានចាប់ផ្តើមបញ្ជូនស្ត្រីប្រកបរបររកស៊ីផ្លូវភេទ ភាគច្រើន ដែលគេចុះចាប់ប្រមូលបានក្នុងប្រតិបត្តិការបោសសម្អាត ទៅកាន់មណ្ឌលដែលគ្រប់គ្រង ដោយអង្គការ មិនមែនរដ្ឋាភិបាល ជាជាងបញ្ជូនទៅកាន់ព្រៃស្ពឺ។ ក៏ប៉ុន្តែ ចាប់តាំពីខែឧសភា ឆ្នាំ២០១០មកយ៉ាងហោចណាស់ស្ត្រីប្រកបរបររកស៊ីផ្លូវភេទ ចំនួនប្រាំបីនាក់ ត្រូវបានគេ ឃុំឃាំងនៅព្រៃស្ពឺ ។ ស្ត្រីប្រកបរបររកស៊ីផ្លូវភេទ ដែលគេឃុំឃាំងខ្លួននៅព្រៃស្ពឺ ក្នុងខែមិថុនា ឆ្នាំ២០១០ ត្រូវបានគេដាក់ឲ្យនៅក្នុងបន្ទប់របស់ពួកគេ ដោយអនុញ្ញាតឲ្យពួកនាងចាកចេញ ពីបន្ទប់ទៅងូតទឹកក្នុងទឹកស្រះដ៏កខ្វក់បានតែពីរដងប៉ុណ្ណោះក្នុងមួយថ្ងៃ ឬក៏ត្រូវគេយាមអមដំណើរតាមជាមួយដោយឆ្មាំមួយនាក់ ទៅកាន់បង្គន់អនាម័យ។

អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានអំពាវនាវដល់រដ្ឋាភិបាលកម្ពុជា ឲ្យបិទជាស្ថាពរនូវមជ្ឈមណ្ឌលសង្គមកិច្ច ដូចជា ព្រៃស្ពឺ ដែលជាកន្លែងឃុំឃាំងប្រជាពលរដ្ឋដោយខុសច្បាប់។ ក្នុងរបាយការណ៍ខែមករាឆ្នាំ២០១០ ដែលមានចំណងជើងថា “ស្បែកដាច់ជាប់ខ្សែភ្លើង” អង្គការឃ្លាំមើលសិទ្ធិមនុស្សបានចងក្រងជាឯកសារផងដែរនូវការរំលោភដ៏សែនរន្ធត់ នៅឯកន្លែងឃុំឃាំងគ្រឿងញៀនក្នុងប្រទេសកម្ពុជាប្រឆាំងនឹងអ្នកប្រើប្រាស់គ្រឿងញៀន។ រដ្ឋាភិបាលកម្ពុជាគួរតែបង្កើតគណៈកម្មាការពិសេសមួយ ដើម្បីស៊ើបអង្កេតយ៉ាងហ្មត់ចត់និងឯករាជ្យនូវអំពើរំលោភទាំងឡាយ និងចាប់ជនប្រព្រឹត្តល្មើសឲ្យមកទទួលខុសត្រូវ។ តាំងពីដើមមក ប៉ូលីសនិងអាជ្ញាធរដទៃទៀត បានរួចខ្លួនពីការទទួលខុសត្រូវចំពោះអំពើរំលោភទាំងនេះ។

ភាសុន បានមានប្រសាសន៍ថា “រដ្ឋាភិបាលកម្ពុជា ត្រូវតែបិទមជ្ឈមណ្ឌលឃុំឃាំងទាំងនេះ ជាបន្ទាន់និងជាស្ថាពរ ដូចជាមជ្ឈមណ្ឌលព្រៃស្ពឺ ដែលជាកន្លែងឃុំឃាំងប្រជាពលរដ្ឋដោយខុសច្បាប់ វាយដំ និងរំលោភ។ ការនាំខ្លួនជនទាំងឡាយ ដែលប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ ទៅវិនិច្ឆ័យទោស  គឺជាការបញ្ជូនសារប្រាប់យ៉ាងខ្លាំងថា ការរំលោភប្រឆាំងនឹង  អ្នកប្រកបរបរ រកស៊ីផ្លូវភេទ មិនអាចអត់ឱនឲ្យបានឡើយ។”

ម្ចាស់ជំនួយដែលគាំទ្រដល់កិច្ចប្រឹងប្រែងប្រឆាំងនឹងការជួញដូរមនុស្ស និងការហ្វឹកហ្វឺន ប៉ូលីស ជាពិសេសសហរដ្ឋអាមេរិក អូស្ត្រាលី ជប៉ុន សហគមន៍អឺរ៉ុប និងអង្គការសហប្រជាជាតិ គួរតែពិនិត្យមើលឡើងវិញនូវមូលនិធិរបស់ខ្លួន ដែលផ្តល់ដល់ប៉ូលីស និងក្រសួងសង្គមកិច្ច រហូតទាល់តែមាន ការស៊ើបអង្កេតមួយដែលឯករាជ្យលើការចោទប្រកាន់ស្តីពី អំពើរំលោភ និងរហូតទាល់តែមានការនាំខ្លួនជនដែលទទួលខុសត្រូវទៅផ្តន្ទាទោស និង រហូតទាល់តែមជ្ឈមណ្ឌលសង្គមកិច្ច ដូចជាព្រៃស្ពឺ ត្រូវបានបិទជាស្ថាពរ។ ទោះជាប្រើពេលច្រើនឆ្នាំសម្រាប់ហ្វឹកហ្វឺនប៉ូលីសក៏ដោយ ក៏ការរំលោភរបស់ប៉ូលីសនៅតែបន្តមាន ទោះជា កងឯកភាពដែលបានហ្វឹកហ្វឺនដោយមានការគាំទ្រពីម្ចាស់ជំនួយអន្តរជាតិក៏ដោយ ដូចជា កងនគរបាលឯកទេសប្រឆាំងការជួញដូរមនុស្សជាដើម។

ភាសុន បានមានប្រសាសន៍ថា “ម្ចាស់ជំនួយគួរតែកុំចំណាយលុយរបស់ពួកគេ ទៅហ្វឹកហ្វឺន មន្ត្រីរំលោភច្បាប់ទាំងអស់នេះ ផ្ទុយទៅវិញគួរតែចាប់បោះជំហានជួយលើកស្ទួយដល់ការទទួលខុសត្រូវពីរដ្ឋាភិបាលកម្ពុជា។”

## **សក្ខីកម្មពីអ្នកប្រកបមុខរបររកស៊ីផ្លូវភេទ ក្នុង “បង្ក្រាបអ្នកប្រកបមុខរបររកស៊ីផ្លូវភេទ”**

នារី  ស្រីស្រស់ប្រកបរបររកស៊ីផ្លូវភេទ បានពិពណ៌នាអំពីការទទួលរងទារុណកម្មពីប៉ូលីស ៖

“មន្ត្រីប៉ូលីសបីនាក់បានវាយដំច្រំធាក់ខ្ញុំយ៉ាងខ្លាំង នៅឯប៉ុស្តិ៍ប៉ូលីសសង្កាត់វត្តភ្នំ បន្ទាប់ពីខ្ញុំត្រូវបានគេនាំខ្លួនពីសួនច្បារ។ ប៉ូលីសម្នាក់ក្នុងចំណោមពួកគេ បានយកកាំភ្លើងមកភ្ជង់ក្បាលខ្ញុំ រួចកេះកៃ ក៏ប៉ុន្តែអត់ផ្ទុះគ្រាប់ទេ។ ពួកគេទាត់កញ្ជឹងករបស់ខ្ញុំ ចង្កេះរបស់ខ្ញុំនិងវាយក្បាលរបស់ខ្ញុំ និងខ្លួនខ្ញុំជាមួយដងអំបោស។ វាយប្រហែលកន្លះម៉ោង។ ខ្ញុំបានសំពះអង្វរពួកគេកុំឲ្យវាយខ្ញុំ។ មន្ត្រីប៉ូលីសឃោរឃៅណាស់ ហើយពួកគេមិនប្រាប់ខ្ញុំពីហេតុផលដែលធ្វើបែបនោះចំពោះខ្ញុំទេ។”

តុលា ដែលមានអាយុ២០ឆ្នាំ បានពិពណ៌នាអំពីរបៀបដែល ប៉ូលីស ជំរិតយកលុយពី ស្ត្រីប្រកបរបររកស៊ីផ្លូវភេទ ៖

“នៅឯស្ថានីយ៍ប៉ូលីសមួយ [ក្នុងខ័ណ្ឌដូនពេញ] ប៉ូលីសបានសួរយើងថាតើ ខ្ញុំមានមេការ [អ្នកគ្រប់គ្រង] ទេ។ ប៉ូលីសអនុញ្ញាតឲ្យខ្ញុំ និងស្ត្រីប្រកបរបររកស៊ីផ្លូវភេទដទៃទៀត ទូរស័ព្ទហៅមេការមកអោយបង់ប្រាក់លោះ [សំណូក] ជាថ្នូរនឹងការដោះលែង។ ស្ត្រីដប់ប្រាំនាក់ក្នុង ចំណោមម្ភៃនាក់ ត្រូវបានគេដោះលែង បន្ទាប់ពីមេការរបស់ពួកគេ យកលុយមកបង់ឲ្យ ប៉ូលីស។ អ្នកនៅសល់ពីហ្នឹង ត្រូវគេទុកនៅឯប៉ុស្តិ៍ប៉ូលីសអស់ពេលបីថ្ងៃ មុនពេលបញ្ជូនទៅ មន្ទីរសង្គមកិច្ច និងបន្ទាប់មកបញ្ជូនទៅមណ្ឌលអង្គការក្រៅរដ្ឋាភិបាល។”

ស្រី ផា អាយុ២៧ឆ្នាំ បានពិពណ៌នាអំពីបទពិសោធន៍របស់នាងនៅឯព្រៃស្ពឺ ៖

“[ព្រៃស្ពឺ ] គឺដូចជាឋាននរកអញ្ចឹង។ ខ្ញុំស្ថិតក្នុងចំណោមមនុស្ស៣០នាក់ ដែលគេចាក់សោរទុកក្នុងបន្ទប់ ដែលមានបុរស ស្ត្រី និងកុមារ។ អត់មានបង្គន់នៅក្នុងបន្ទប់ទេ ប៉ុន្តែមានធុងពីរដែលគេប្រើវាជាបង្គន់សម្រាប់ប្រើទាំងអស់គ្នា។ មានឈាមប្រឡាក់ពេញលើជញ្ជាំង។ ខ្ញុំដេក មិនលក់ទេនៅពេលយប់ ព្រោះខ្ញុំខ្លាចនិងព្រួយ។ ខ្ញុំទទួលបានអាហារបន្តិចបន្តួច ហូបពីរពេលក្នុងមួយថ្ងៃ - បាយជាមួយប្រហុក (ត្រីដែលគេផ្អាប់ទុក) និងផ្លែអម្ពិល។ មិនមានចាន បាយ ឬស្លាបព្រាទេ  ខ្ញុំត្រូវហូបពីថង់ផ្លាស់ស្ទិក។ នៅពេលយប់ ឆ្មាំបានវាយយ៉ាងធ្ងន់ធ្ងរទៅលើបុរសម្នាក់ ដែលបានព្យាយាមរត់គេចខ្លួន។”

នីកា អាយុ២៨ឆ្នាំ ពិពណ៌នាអំពីការវាយដំដោយឆ្មាំសន្តិសុខសួនច្បាររាជធានី ៖

“សន្តិសុខម្នាក់ដំបូងបានមក និងទាត់ខ្ញុំ ហើយនិយាយថា “ហេតុអី?” បន្ទាប់មកឆ្មាំបីនាក់ទៀតបានមកដល់។ អ្នកយាមពីរនាក់ចាប់ដៃទាំងពីររបស់ខ្ញុំ ដោយទុកឲ្យពីរនាក់ទៀតវាយខ្ញុំ។ ពួកគេទះមុខខ្ញុំ។ ពួកគេដូចជាស្រវឹងស្រាបន្តិច។ ពួកគេវ៉ៃក្បាលខ្ញុំនឹងដំបងឫស្សី និងវិទ្យុរបស់ពួកគេ និងវាយសព្វកន្លែងទាំងអស់។ ពួកគេចាប់ហែកអាវខ្ញុំ។ ប៉ូលីសបានមក កាត់តាមនោះ តែគេអត់រវល់នឹងខ្ញុំទេ។ សន្តិសុខបន្តវាយខ្ញុំជិតកន្លះម៉ោង។ មនុស្សជាច្រើននាក់ឃើញខ្ញុំ តែគេរាល់គ្នាខ្លាច មិនហ៊ានជួយខ្ញុំទេ។ ប្រធានសន្តិសុខ
ប្រាប់កូនចៅផ្សេងទៀតថាបើឃើញខ្ញុំនៅទីនោះម្តងទៀត ត្រូវវាយខ្ញុំឲ្យងាប់។